# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យចម្លងនៅគិរីរម្យ
# ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨

អត្ថបទទី១៖ កក ១០,៣៤.៣៧-៤៣
អត្ថបទទី២៖ កូឡ ៣,១-៤
ដំណឹងល្អ៖ លក ២៤,១៣-៣៥

បងប្អូនជាទីស្រឡាញ់!

អាលេលូយ៉ា! អាលេលូយ៉ា! ព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញហើយ មានន័យយ៉ាងណាសម្រាប់ជីវិតរបស់យើង ដែលខិតខំស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ពីមួយថ្ងៃទៅមួយថ្ងៃ? មានន័យដូចម្តេច ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ? នេះជាដំណឹងល្អដល់កំពូលសម្រាប់ជីវិតរបស់យើង នៅក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទ យើងមានពិធីបុណ្យពីរសំខាន់បំផុត គឺបុណ្យព្រះយេស៊ូប្រសូត និងបុណ្យចម្លង។ ពីព្រះយេស៊ូប្រសូតហើយ ព្រះអង្គនៅស្ងៀមស្ងាត់៣០ឆ្នាំ ដោយធ្វើជាជាងឈើរស់នៅជាជីវិតធម្មតាជាមួយលោកយ៉ូសែបនិងព្រះនាងម៉ារី។ ប៉ុន្តែមានថ្ងៃមួយ ព្រះយេស៊ូបានចាប់ផ្តើមចេញពីភូមិណាសារ៉ែត ដើម្បីធ្វើដំណើរពីភូមិមួយទៅភូមិមួយ ដោយណែនាំឲ្យមនុស្សខ្វាក់មើលឃើញមនុស្សខ្វិនដើរបាន អ្នកជំងឺបានជាសះស្បើយ ...។ ដូច្នេះ ពេលព្រះយេស៊ូដើរពីភូមិមួយទៅភូមិមួយ ព្រះយេស៊ូបានណែនាំឲ្យមនុស្សសប្បាយចិត្តណាស់ ដោយមានមហាជនដើរតាមព្រះយេស៊ូច្រើនណាស់ ព្រោះគេឃើញព្រះអង្គបានណែនាំឲ្យគេមានសេចក្តីសង្ឃឹម ព្រះយេស៊ូណែនាំឲ្យគេមានជីវិតថ្មី ព្រះយេស៊ូណែនាំឲ្យគេមានម្ហូបអាហារយ៉ាងបរិបូរណ៍។ ប៉ុន្តែហេតុអ្វីគេសម្លាប់ព្រះយេស៊ូ? តើព្រះយេស៊ូបានធ្វើអ្វីខុស? ដោយសារគេលឺព្រះយេស៊ូមានព្រះបន្ទូលថា **ខ្ញុំជាព្រះជាម្ចាស់ ខ្ញុំជាព្រះបុត្រារបស់ព្រះជាម្ចាស់** គេមិនយល់ព្រះយេស៊ូជាមនុស្សធម្មតាដែលមកពីភូមិណាសារ៉ែត ដោយស្គាល់ម្តាយឈ្មោះ ម៉ារី ឪពុកឈ្មោះ យ៉ូសែប មូលហេតុអ្វីបានជាគាត់និយាយថាគាត់ជាព្រះបុត្រារបស់ព្រះជាម្ចាស់? គេមិនអាចទទួលបាន ទើបគេចាប់ព្រះយេស៊ូនឹងសម្លាប់ព្រះអង្គ។ ហេតុនេះហើយអស់អ្នកដែលបានទទួលការសង្គ្រោះពីព្រះអង្គ ទាំងអ្នកជំងឺ ទាំងជនពិការ ទាំងអ្នកដែលអស់សង្ឃឹមនៅក្នុងជីវិត គេនៅក្បែរឈើឆ្កាងហើយគេយំដោយសារ គេសោគស្តាយការបាត់បង់ជីវិតរបស់ព្រះយេស៊ូ។ ព្រះយេស៊ូនៅជាមួយគេតែ៣ឆ្នាំ ដែលបានណែនាំឲ្យជីវិតរបស់គេមានសេចក្តីសុខ។ ថ្ងៃអាទិត្យមុន យើងធ្វើបុណ្យហែរដើម្បីច្រៀងកោតសរសើរព្រះយេស៊ូគ្រីស្ត ដោយ

ស្រែកថា **ជយោ! ព្រះរាជវង្សព្រះបាទដាវីឌ**ដោយសារយើងថាព្រះយេស៊ូជាព្រះមហាក្សត្រយើង ព្រះយេស៊ូយាងមកដើម្បីឲ្យយើងមានសេចក្តីសុខ ព្រះយេស៊ូយាងមកដើម្បីគ្រប់គ្រងជីវិតរបស់យើង។ ប៉ុន្តែក្រោយមកគេសម្លាប់ព្រះយេស៊ូ ដោយអស់អ្នកដែលបានច្រៀងលើកតម្កើងព្រះយេស៊ូ បែរមកស្រែកឲ្យគេឆ្កាងព្រះយេស៊ូទៅវិញ។

ព្រឹកឡើង មានស្ត្រីមួយចំនួនបានធ្វើដំណើរទៅរូងថ្មដែលគេដាក់សពព្រះយេស៊ូ ពេលគេទៅដល់ផ្នូរគេភ្ញាក់ដោយសាររូងថ្មនេះ គេបានយកផ្ទាំងថ្មមួយយ៉ាងធំមកបិទមាត់រូងហើយ ប៉ុន្តែរូងថ្មនេះតែជាចំហរទៅវិញ។ ពេលគេចូលនៅក្នុងរូងថ្មនោះ គេមិនបានឃើញសពព្រះយេស៊ូទេ តែមានទេវទូតពីរដែលប្រាប់ថា " **ព្រះអង្គយាងទៅស្រុកកាលីឡេមុនអ្នករាល់គ្នា។ នៅទីនោះអ្នករាល់គ្នានឹងឃើញព្រះអង្គ ដូចទ្រង់មានព្រះបន្ទូលទុកស្រាប់**" គឺព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

អាលេលូយ៉ា! អាលេលូយ៉ា! ព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញហើយ នេះជាដំណឹងល្អដែលយើងស្តាប់យប់នេះ។ នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត ព្រះអង្គបានចាប់កំណើតជាមនុស្ស ថ្ងៃសុក្រពិសិដ្ឋព្រះយេស៊ូស្លាប់ ប៉ុន្តែថ្ងៃនេះយើងបានទទួលដំណឹងអស្ចារ្យគឺព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូមានព្រះរស់ឡើងវិញ ដើម្បីណែនាំឲ្យយើងទាំងអស់ពោរពេញដោយសេចក្តីសង្ឃឹមរហូតមកដល់សព្វថ្ងៃ។ រឿងដែលយើងបានស្តាប់ថ្ងៃនេះ គឺបានកើតឡើងជាង២០០០ឆ្នាំហើយ ប៉ុន្តែថ្ងៃនេះយើងមកជួបជុំគ្នាដើម្បីចូលរួមច្រៀង អាលេលូយ៉ាង! អាលេលូយ៉ា! ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ។ ២០០០ឆ្នាំហើយ ដែលយើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង និងណែនាំឲ្យយើងទាំងអស់មានសេចក្តីសង្ឃឹមនៅក្នុងជីវិត។ ព្រះយេស៊ូណែនាំឲ្យយើងមានជីវិតថ្មី នៅភូមិសុខសាន្ត មានយុវនារីម្នាក់អាយុ១៨ឆ្នាំ ជាមនុស្សថ្លង់និយាយមិនបាន ពីរឆ្នាំមុនគាត់អាចនិយាយបាន។ ពីរខែមុន ប្អូនរបស់គាត់ម្នាក់ទៀតដែលនិយាយមិនបានដូចគ្នា បែរមកនិយាយបានទៀត នេះជាការអស្ចារ្យដែលព្រះជាម្ចាស់បានបង្ហាញឲ្យយើងឃើញដោយសារគេសប្បាយចិត្ត គេមានការងារធ្វើ គេមានមិត្តភ័ក្តិ គេមានមនុស្សស្រឡាញ់រាប់អានគេច្រើន។ យប់នេះយើងពោរពេញដោយអំណរសប្បាយ ដោយសារព្រះយេស៊ូណែនាំឲ្យយើងមានជីវិត។ កូនកាយរិទ្ធិ មកកម្មវិធីកាយរិទ្ធិរាល់សប្តាហ៍ដើម្បីលេង ដើម្បីសប្បាយរួមជាមួយគ្នា ដោយសារនៅទីនេះយើងរកឃើញគ្រួសារថ្មីមួយ យើងធ្វើដូចម្តេច

ដើម្បីបង្ហាញជីវិតរបស់ព្រះយេស៊ូ ដែលណែនាំយើងពោរពេញដោយសេចក្តីសុខ។ នៅក្នុងជីវិតរបស់យើងមានទុក្ខលំបាកច្រើន នៅក្នុងក្រុមគ្រួសារក្តី នៅក្នុងសង្គមក្តី នៅក្នុងពិភពលោកក្តី យប់នេះឲ្យយើងយល់ថា យើងធ្វើដូចម្តេចដើម្បីទៅជាសាក្សីនៃសេចក្តីសង្ឃឹម។ បើយើងមិនចាប់ផ្តើម សេចក្តីសង្ឃឹមមកពីណា? បើយើងមិនខិតខំធ្វើអ្វីមួយដើម្បីឲ្យបងប្អូនមានសេចក្តីសុខ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញគ្មានន័យសោះ។ នៅផ្ទះខ្ញុំនៅភ្នំពេញថ្មី ខ្ញុំបានរៀបចំសួនច្បារមួយ ដែលមានផ្កាច្រើន ដែលមានសត្វព្រាប សត្វពស់ សត្វមាន់ សត្វសេក ត្រី... ប៉ុន្មានថ្ងៃមុនមាននិស្សិតមកពីវិទ្យាស្ថានសន្តប៉ូលគេមកលេង គេប្រាប់ខ្ញុំថាពេលអង្គុយនៅទីនេះមានសេចក្តីសុខណាស់។ ដូច្នេះ នៅព្រះសហាគមន៍របស់យើងរៀបចំកន្លែងស្អាតដើម្បីឲ្យបងប្អូនមានសេចក្តីសុខ។ នៅក្នុងជីវិតយើង ឲ្យយើងយកចិត្តទុកដាក់ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗមានសេចក្តីសុខ។ យើងដឹងថា ដើម្បីឲ្យប្រទេសរបស់យើងរីកចម្រើន ស៊ីសងយើងរៀងៗខ្លួនបើយើងមិនយកចិត្តទុកដាក់គឺគ្មានអ្វីសោះ ដូច្នេះមានតែយុវសិស្សជំនាន់ក្រោយៗនេះត្រូវតែខិតខំរៀនសូត្រ ត្រៀមខ្លួនដើម្បីធ្វើជាអ្នកដែលណែនាំឲ្យប្រទេសកម្ពុជាមានសេចក្តីសុខ និងភាពរីកចម្រើន។ យើងធ្វើដូចម្តេចដើម្បីណែនាំឲ្យក្រុមគ្រួសាររបស់យើងមានសេចក្តីសុខ? យើងធ្វើដូចម្តេចដើម្បីណែនាំឲ្យប្រទេសរបស់យើងរីកចម្រើន? យើងទទួលខុសត្រូវខ្ពស់លើការងាររបស់យើង។

យប់នេះយើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គជួយយើង ដោយដឹងថាព្រះអង្គប្រទានឲ្យយើងមានជីវិត ព្រះអង្គប្រទានឲ្យយើងមានសេចក្តីសុខ យើងធ្វើដូចម្តេចឲ្យគ្រួសាររបស់យើង សង្គមរបស់យើង ពិភពលោករបស់យើង ទៅជាគ្រួសារអស្ចារ្យ ទៅជាសង្គមអស្ចារ្យ ទៅជាពិភពលោកអស្ចារ្យ។ យើងដឹងថាធម្មជាតិដែលយើងបានទទួល ជាកាដូដែលយើងបានពីព្រះជាម្ចាស់ ហេតុនេះហើយយើងត្រូវតែរួមគ្នាថែរក្សាធម្មជាតិ។ យើងអាចធ្វើបានច្រើន ដើម្បីណែនាំឲ្យជីវិតរបស់យើងពោរពេញដោយភាពសុខដមរនា នេះជាអត្ថន័យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ យើងអរព្រះគុណព្រះជាម្ចាស់ យើងពោរពេញដោយអំណរសប្បាយ តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យគ្រួសាររបស់ខ្ញុំ សង្គមរបស់ខ្ញុំ ពិភពលោករបស់ខ្ញុំ ទៅជាគ្រួសារ សង្គម ពិភពលោកស្អាតនិងពោរពេញដោយសេចក្តីសង្ឃឹម និងអំណរសប្បាយ។ អាលេលូយ៉ា! អាលេលូយ៉ា! ព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញហើយ។ អាម៉ែន៕